# ក្ដារចុចខ្មែរអង្គរ

## មាតិកា

**សេចក្ដីផ្ដើម** .......... 2
**ស្រទាប់នីមួយៗនៃក្ដារចុចខ្មែរអង្គ** .......... 2
  **ស្រទាប់នីមួយៗលើខែសថប –វីនដូស៍/ម៉ាកអូអេស** .......... 2
  **ស្រទាប់នីមួយៗលើឧបករណ៍ថាច់ (touch) –អ៊ែនដ្រយ /អាយអូអេស** .......... 3
តួអក្សរខ្មែរតាមក្រុម និង គ្រាប់ចុចសម្រាប់ខែសថប .......... 6
  ព្យញ្ជនៈ .......... 6
  ស្រៈនិស្ស័យ .......... 6
  សញ្ញា .......... 7
  ស្រៈពេញតួ .......... 7
  វណ្ណយុត្ត .......... 7
  ខណ្ឌសញ្ញាខ្មែរ .......... 7
  ខណ្ឌសញ្ញាឡាតាំង .......... 7
  សញ្ញារូបិយបណ្ណ .......... 8
  លេខខ្មែរ .......... 8
  លេខអត្ថៈ .......... 8
  លេខកាលបរិច្ឆេទចន្ទគតិខ្មែរ .......... 8
  តួអក្សរហួសសម័យ(លែងប្រើ) .......... 9
  តួអក្សរប្រើក្នុងភាសាជនជាតិដើមភាគតិច .......... 9
  ការភ្ជាប់ និង ដំណកឃ្លា .......... 9
ការវាយអក្សរខ្មែរ .......... 10
  ស្វ័យកែតម្រូវដោយគ្មានការរំខាន .......... 10
    ជើង + ស្រៈ .......... 10
    ជើង + ្រ [U+17D2] [U+179A] .......... 10
    ជើង + វណ្ណយុត្តប្ដូរមូលភេទ + ស្រៈ .......... 11
    វណ្ណយុត្តប្ដូរមូលភេទ + ស្រៈ .......... 11
    ស្រៈមាននិគហិត [U+17C6] .......... 11
    ស្រៈ ោ [U+17C4] និងស្រៈ ើ [U+17BE] .......... 11
    ជើងមើលទៅដូចគ្នា .......... 11
  ការបង្វិលស្រៈ .......... 11
  បម្រាម/សំឡេងព្រមាន .......... 12
  តួអក្សរវាយច្រឡំ .......... 12

# សេចក្ដីផ្ដើម

ឯកសារនេះត្រូវបានដកស្រង់និងសម្រួលមកពីពប្រភព ៖ «របៀបវាយយូនីកូដខ្មែរ» «យូនីកូដស្តង់ដា កំណែ១0.0.0» និង អត្ថបទស្រាវជ្រាវដែលក្រុមការងារឃីមែនបានសរសេរនិងធ្វើបទបង្ហាញនៅសន្និសិទ្ធអាស៊ីស្ដីពីប្រព័ន្ធព័ត៌មាននៅឆ្នាំ ២០១៧ក្រោមចំណងជើងថា «ភាពងាយរងគ្រោះដោយការវែនឌើរក្នុងការប្រើប្រាស់យូនីកូដខ្មែរ» ។ ការកែកុនបន្ថែមធ្វើឡើងដោយក្រុមការងារឃីមែន ។ ស្រទាប់១ត្រូវបានបន្ថែមលើកម្មវិធីសម្រាប់ខែសថបនិងឧបករណ៍ថាច់ដើម្បីដាក់លេខខ្មែរបុរាណដែលប្រើសម្រាប់ការទស្សទាយនិងការបរិច្ចេទចន្ទគតិ ។

# ស្រទាប់នីមួយៗនៃក្ដារចុចខ្មែរអង្គ

## ស្រទាប់នីមួយៗលើខែសថប –វីនដូស៍/ម៉ាកអូអេស

ស្រទាប់ដើម




ស្រទាប់ពេលចុចប្ដូរ (Shift)



ស្រទាប់ពេលចុចឆ្លាស់ស្ដាំ (AltGr)




ស្រទាប់ពេលចុចឆ្លាស់ស្ដាំ(AltGr)និងប្ដូរ(Shift)ព្រមគ្នា




## ស្រទាប់នីមួយៗលើឧបករណ៍ថាច់ (touch) –អ៊ែនដ្រយ /អាយអូអេស

គ្មានគ្រាប់ចុចប្ដូរស្រទាប់(Shift key) ហើយគ្មានគ្រាប់ចុចដាក់ជើងទេ ។ ប្លែកណាស់ មែនទេ? ប្រហែលហើយ តែតាមពិតទៅ យើងពិបាកចុចគ្រាប់ចុចប្ដូរស្រទាប់ណាស់ពេលប្រើដៃម្ខាង ។ គ្រាប់ចុចផ្សេងទៀតបង្កប់នៅក្នុងគ្រាប់ចុចនីមួយៗ បើចុចឱ្យយូរ(ប្រហែល១វិនាទី) យើងនឹងឃើញគ្រាប់ចុចច្រើនទៀតលេចឡើង ។ ឧទាហរណ៍ ដើម្បីបានជើង “្រ” “ឫ” ឬ “ឬ” យើងត្រូវចុចគ្រាប់ចុច “រ” ឱ្យជាប់ ហើយរើសយកគ្រាប់ចុច “្រ” ដែលផុសឡើង ។ យើងប្រហែលជាចំណាំបានថានៅលើក្ដារចុចខ្មែរអង្គុរសម្រាប់ឌែសថប តួអក្សរទាំង៤នេះសុទ្ធតែស្ថិតនៅលើគ្រាប់ចុច “R” ហេតុដូច្នេះហើយបានជាគេយកវាមកដាក់លើគ្រាប់ចុចនេះដោយបង្កប់ក្នុងមុខងារឡុងប្រេស (long press) ។

ពេលប្រើក្ដារចុចបែបថាច់ យើងគប្បីដឹងពីទីតាំងនៃគ្រាប់ចុចនីមួយៗ ។ ប្រហែលត្រូវការពេលខ្លះដើម្បីឱ្យស៊ាំនឹងការប្រើប្រាស់បែបនេះ តែវានឹងងាយទៅៗ ពេលដែលយើងប្រើវាយូរបន្តិច ហើយវានឹងងាយជាងការចុចលើ “Shift” ដើម្បីប្ដូរទៅស្រទាប់មួយទៀតរាល់ពេលដើម្បីរកមើលគ្រាប់ចុចផ្សេងទៀត ដូចគ្នាដែរយើងមិនបាច់ចុចលើ “្” រាល់លើកដើម្បីដាក់ជើងទេ ។

ស្រទាប់ដើម




ស្រទាប់លេខ (១២៣)




ស្រទាប់លេខអត្ថៈ និង ការបរិច្ឆេទចន្ទគតិខ្មែរ (᧠᧡᧢)



## តួអក្សរខ្មែរតាមក្រុម និង គ្រាប់ចុចសម្រាប់ឌែសថប

### ព្យញ្ជនៈ

| ព្យញ្ជនៈ | គ្រាប់ចុច |
|---|---|
| ក [U+1780] | K |
| ខ [U+1781] | X |
| គ [U+1782] | Shift K |
| ឃ [U+1783] | Shift X |
| ង [U+1784] | G |
| ច [U+1785] | C |
| ឆ [U+1786] | Q |
| ជ [U+1787] | Shift C |
| ឈ [U+1788] | Shift Q |
| ញ [U+1789] | Shift J |
| ដ [U+178A] | D |
| ឋ [U+178B] | Z |
| ឌ [U+178C] | Shift D |
| ឍ [U+178D] | Shift Z |
| ណ [U+178E] | Shift N |
| ត [U+178F] | T |
| | |

| ព្យញ្ជនៈ | គ្រាប់ចុច |
|---|---|
| ថ [U+1790] | F |
| ទ [U+1791] | Shift T |
| ធ [U+1792] | Shift F |
| ន [U+1793] | N |
| ប [U+1794] | B |
| ផ [U+1795] | P |
| ព [U+1796] | Shift B |
| ភ [U+1797] | Shift P |
| ម [U+1798] | M |
| យ [U+1799] | Y |
| រ [U+179A] | R |
| ល [U+179B] | L |
| វ [U+179C] | V |
| ស [U+179F] | S |
| ហ [U+17A0] | H |
| ឡ [U+17A1] | L |
| អ [U+17A2] | Shift G |

### ស្រៈនិស្ស័យ

| ស្រៈនិស្ស័យ | គ្រាប់ចុច |
|---|---|
| ◌ា [U+17B6] | A |
| ◌ិ [U+17B7] | I |
| ◌ី [U+17B8] | Shift I |
| ◌ឹ [U+17B9] | W |
| ◌ឺ [U+17BA] | Shift W |
| ◌ុ [U+17BB] | O |
| ◌ូ [U+17BC] | Shift O |
| ◌ួ [U+17BD] | Shift Y |
| ◌ើ [U+17BE] | ; |
| ◌ឿ [U+17BF] | Shift [ |
| | |

| ស្រៈនិស្ស័យ | គ្រាប់ចុច |
|---|---|
| ◌ៀ [U+17C0] | [ |
| ◌េ [U+17C1] | E |
| ◌ែ [U+17C2] | Shift E |
| ◌ៃ [U+17C3] | Shift S |
| ◌ោ [U+17C4] | O |
| ◌ៅ [U+17C5] | Shift O |
| ◌ុំ [U+17BB] [U+17C6] | , |
| ◌ាំ [U+17B6] [U+17C6] | Shift A |
| ◌ុះ [U+17BB] [U+17C7] | Shift , |
| ◌េះ [U+17C1] [U+17C7] | Shift V |
| ◌ោះ [U+17C4] [U+17C7] | Shift ; |

## សញ្ញា

| សញ្ញា | គ្រាប់ចុច |
|---|---|
| ំ [U+17C6] | Shift M |
| ះ [U+17C7] | Shift H |
| ៈ [U+17C8][1] | AltGr ' |

## ស្រះពេញតួ

| ស្រះពេញតួ | គ្រាប់ចុច |
|---|---|
| ឥ [U+17A5] | - |
| ឦ [U+17A6] | AltGr I |
| ឧ [U+17A7] | Shift ] |
| ឩ [U+17A9] | AltGr [ |
| ឪ [U+17AA] | ] |
| ឫ [U+17AB] | AltGr R |
| ឬ [U+17AC] | Shift R |

| ស្រះពេញតួ | គ្រាប់ចុច |
|---|---|
| ឭ [U+17AD] | Shift \ |
| ឮ [U+17AE] | \ |
| ឯ [U+17AF] | AltGr E |
| ឰ [U+17B0] | AltGr P |
| ឱ [U+17B1] | AltGr O |
| ឲ [U+17B2] | = |
| ឳ [U+17B3] | AltGr ] |

## វណ្ណយុត្ត

| វណ្ណយុត្ត | គ្រាប់ចុច |
|---|---|
| ៉ [U+17C9] | Shift ' |
| ៊ [U+17CA] | / |
| ់ [U+17CB] | ' |
| ៌ [U+17CC] | Shift - |
| ៍ [U+17CD] | Shift 6 |

| វណ្ណយុត្ត | គ្រាប់ចុច |
|---|---|
| ៏ [U+17CF] | Shift 8 |
| ័ [U+17D0] | Shift 7 |
| ៎ [U+17CE] | AltGr = |
| ៓ [U+17D3] | AltGr M |
| ្ [U+17D2] | J |

## ខណ្ឌសញ្ញាខ្មែរ

| ខណ្ឌសញ្ញាខ្មែរ | គ្រាប់ចុច |
|---|---|
| ។ [U+17D4] | . |
| ៕ [U+17D5] | Shift . |
| ៖ [U+17D6] | AltGr ; |

| ខណ្ឌសញ្ញាខ្មែរ | គ្រាប់ចុច |
|---|---|
| ៙ [U+17D9] | AltGr 6 |
| ៚ [U+17DA] | AltGr 7 |
| ៗ [U+17D7] | Shift 2 |

## ខណ្ឌសញ្ញាឡាតាំង

| ខណ្ឌសញ្ញាឡាតាំង | គ្រាប់ចុច |
|---|---|
| ! [U+0021] | Shift 1 |
| ? [U+003F] | Shift ? |

| ខណ្ឌសញ្ញាឡាតាំង | គ្រាប់ចុច |
|---|---|
| « [U+00AB] | ` |
| » [U+00BB] | Shift ` |

[1] តាមពិត វាមិនមែនជាស្រះទេ តែវាមានតួនាទីស្រដៀងស្រះ ។ ជួនកាលគេចាត់ទុកថាវាជាវណ្ណយុត្ត ។

| | | | |
|---|---|---|---|
| “ [U+0022] | Shift 3 | - [U+002D] | AltGr S |
| . [U+002E] | AltGr . | : [U+003A] | AltGr G |
| , [U+002C] | AltGr , | ‘ [U+2018] | AltGr H |
| ; [U+003B] | AltGr N | ’ [U+2019] | AltGr J |
| # [U+0023] | AltGr C | & [U+0026] | AltGr V |

## សញ្ញារូបិយបណ្ណ

| | |
|---|---|
| ៛ [U+17DB] | Shift 4 |

## លេខខ្មែរ

| លេខខ្មែរ | គ្រាប់ចុច |
|---|---|
| ១ [U+17E1] | 1 |
| ២ [U+17E2] | 2 |
| ៣ [U+17E3] | 3 |
| ៤ [U+17E4] | 4 |
| ៥ [U+17E5] | 5 |

| លេខខ្មែរ | គ្រាប់ចុច |
|---|---|
| ៦ [U+17E6] | 6 |
| ៧ [U+17E7] | 7 |
| ៨ [U+17E8] | 8 |
| ៩ [U+17E9] | 9 |
| ០ [U+17E0] | 0 |

## លេខអត្ថៈ

| លេខអត្ថៈ | គ្រាប់ចុច |
|---|---|
| ៱ [U+17F1] | AltGr Shift 1 |
| ៲ [U+17F2] | AltGr Shift 2 |
| ៳ [U+17F3] | AltGr Shift 3 |
| ៴ [U+17F4] | AltGr Shift 4 |
| ៵ [U+17F5] | AltGr Shift 5 |

| លេខអត្ថៈ | គ្រាប់ចុច |
|---|---|
| ៶ [U+17F6] | AltGr Shift 6 |
| ៷ [U+17F7] | AltGr Shift 7 |
| ៸ [U+17F8] | AltGr Shift 8 |
| ៹ [U+17F9] | AltGr Shift 9 |
| ៰ [U+17F0] | AltGr Shift 0 |

## លេខកាលបរិច្ឆេទចន្ទគតិខ្មែរ

| លេខកាលបរិច្ឆេទចន្ទគតិ | គ្រាប់ចុច |
|---|---|
| ᧠ [U+19E0] | AltGr Shift Q |
| ᧡ [U+19E1] | AltGr Shift W |
| ᧢ [U+19E2] | AltGr Shift E |
| ᧣ [U+19E3] | AltGr Shift R |
| ᧤ [U+19E4] | AltGr Shift T |
| ᧥ [U+19E5] | AltGr Shift Y |
| ᧦ [U+19E6] | AltGr Shift U |
| ᧧ [U+19E7] | AltGr Shift I |

| លេខកាលបរិច្ឆេទចន្ទគតិ | គ្រាប់ចុច |
|---|---|
| ᧰ [U+19F0] | AltGr Shift G |
| ᧱ [U+19F1] | AltGr Shift H |
| ᧲ [U+19F2] | AltGr Shift J |
| ᧳ [U+19F3] | AltGr Shift K |
| ᧴ [U+19F4] | AltGr Shift L |
| ᧵ [U+19F5] | AltGr Shift ; |
| ᧶ [U+19F6] | AltGr Shift ’ |
| ᧷ [U+19F7] | AltGr Shift Z |

| លេខកាលបរិច្ឆេទចន្ទគតិ | គ្រាប់ចុច |
|---|---|
| ᧨ [U+19E8] | AltGr Shift O |
| ᧩ [U+19E9] | AltGr Shift P |
| ᧪ [U+19EA] | AltGr Shift [ |
| ᧫ [U+19EB] | AltGr Shift ] |
| ᧬ [U+19EC] | AltGr Shift A |
| ᧭ [U+19ED] | AltGr Shift S |
| ᧮ [U+19EE] | AltGr Shift D |
| ᧯ [U+19EF] | AltGr Shift F |

| លេខកាលបរិច្ឆេទចន្ទគតិ | គ្រាប់ចុច |
|---|---|
| ᧸ [U+19F8] | AltGr Shift X |
| ᧹ [U+19F9] | AltGr Shift C |
| ᧺ [U+19FA] | AltGr Shift V |
| ᧻ [U+19FB] | AltGr Shift B |
| ᧼ [U+19FC] | AltGr Shift N |
| ᧽ [U+19FD] | AltGr Shift M |
| ᧾ [U+19FE] | AltGr Shift , |
| ᧿ [U+19FF] | AltGr Shift . |

## តួអក្សរហួសសម័យ(លែងប្រើ)

| តួអក្សរ | គ្រាប់ចុច |
|---|---|
| ៘ [U+17D8] | AltGr L |
| ឨ [U+17A8] | AltGr T |
| ៜ [U+17DC] | AltGr Q |
| ៑[2] [U+17D1] | AltGr 3 |
| ៓ [U+17D3] | AltGr M |

## តួអក្សរប្រើក្នុងភាសាជនជាតិដើមភាគតិច

| តួអក្សរ | គ្រាប់ចុច |
|---|---|
| ឝ [U+179D] | AltGr K |
| ឞ [U+179E] | AltGr B |
| ៝ [U+17DD] | AltGr W |

## ការភ្ជាប់ និង ដំណកឃ្លា

| ឈ្មោះគ្រាប់ចុច | គ្រាប់ចុច |
|---|---|
| ចន្លោះមើលមិនឃើញ មិនភ្ជាប់ (Zero-width non-joiner) [U+200C] | Ctrl + Alt + 1 |
| ចន្លោះមើលមិនឃើញ ភ្ជាប់ (Zero-width joiner) [U+200D] | Ctrl + Alt + ‘ |
| ចន្លោះមើលមិនឃើញ (Zero-width space) [U+200B] | Spacebar |
| ដំណកឃ្លា (White space) [U+0020] | Shift + Spacebar |
| គ្មានដំណកឃ្លា (No break space) [U+00A0] | Ctrl + Alt + Spacebar |

[2] សូមកុំច្រឡំតួអក្សរនេះនឹងត្រីសព្ទ ៊ [U+17CA] ។

# ការវាយអក្សរខ្មែរ

ក្ដារចុចខ្មែរអង្គរតម្រៀបគ្រាប់ចុចតាមក្ដារចុចខ្មែរណែដា(Khmer NiDA) ហើយក៏បានធ្វើការកែសម្រួលបន្ថែមទៀត ។ លក្ខណៈពិសេសផ្សេងៗបានដាក់បញ្ចូលដើម្បីជួយសម្រួលដល់ការវាយអក្សរខ្មែរ (ឧទា. កាត់បន្ថយការវាយដែលមានលំដាប់លំដោយតួអក្សរមិនកុងសង់ស៊ីសគ្នា) ។ មិនថាអ្នកវាយអក្សរបែបណាទេដើម្បីឱ្យចេញជាពាក្យ ក្ដារចុចនេះនឹងធ្វើឱ្យពាក្យនោះត្រឹមត្រូវតាមលំដាប់លំដោយដែលបានកំណត់រួចជាស្រេច ។ សូមចំណាំផងដែរថាការស្វ័យកែសម្រួលនេះមានប្រសិទ្ធភាពចំពោះតែករណីដែលបានបញ្ចូលក្នុងក្ដារចុចនេះប៉ុណ្ណោះ ។ សូមចុចទីនេះដើម្បីបើកមើលការណែនាំពីរបៀបដំឡើងក្ដារចុចខ្មែរអង្គរ ។

របៀបប្រើប្រាស់ក្ដារចុចខ្មែរអង្គរគឺមិនខុសពីរបៀបប្រើប្រាស់ក្ដារចុចផ្សេងៗទៀតដែលប្រើការតម្រៀបគ្រាប់ចុចតាមខ្មែរណែដានោះឡើយ ។ អ្នកអាចវាយពាក្យ១តាមលំដាប់លំដោយនៃការប្រកប មិនមែនតាមរបៀបដែលវាបង្ហាញឱ្យយើងឃើញទេ ជាពិសេសពេលស្រៈស្ថិននៅខាងឆ្វេងព្យញ្ជនៈ ។ ដើម្បីវាយពាក្យ “តែ” យើងត្រូវវាយព្យញ្ជនៈមុនហើយទើបវាស្រៈ (បានន័យថា វាយគ្រាប់ចុច “T” បន្ទាប់មក “Shift E”) ។

លំដាប់លំដោយនៃតួអក្សរគឺ ៖

**ព្យព្ជនៈ+ជើងព្យញ្ជនៈ+វណ្ណយុត្តប្ដូរមូលភេទ+ស្រៈ+វណ្ណយុត្ត**

## ស្វ័យកែតម្រូវដោយគ្មានការរំខាន

ក្ដារចុចខ្មែរអង្គរនឹងកែតម្រូវដោយស្វ័យប្រវត្តិនូវកំហុសនៃការវាយអក្សរខ្មែរចំនួន៨ករណី ។ ករណីទាំងនេះសុទ្ធតែមិនអាចមើលឃើញនឹងភ្នែកទទេ ហើយកម្មវិធីបង្ហាញអក្សរលើអេក្រង់(rendering engine)នឹងមិនបង្ហាញឱ្យយើងឃើញនូវកំហុសទាំងនោះនៅលើអេក្រង់ទេ ។ ការស្វ័យកែតម្រូវនេះប្រព្រឹត្តិទៅដោយធ្វើការតម្រៀងតួអក្សរឡើងវិញឬក៏ប្ដូរតួអក្សរដែលខុសទៅជាតួអក្សរមួយទៀតដែលត្រឹមត្រូវពិតប្រាកដក្នុងមួយប៉ព្រិចភ្នែក ។

### ជើង + ស្រៈ

ពេលជើងនិងស្រៈនៅជិតគ្នា ស្រៈត្រូវនៅបន្ទាប់ពីជើង ។ ឧទាហរណ៍ “ខ្មែរ” និង “ខ្មែរ” មើលទៅដូចគ្នាបេះបិទ ប៉ុន្តែការវាយបញ្ចូលរបស់វាមិនដូចគ្នាទេ ។

1. ខ្មែរ = ខ ◌្ម ◌ែ រ (ត្រូវ)
2. ខ្មែរ = ខ ◌ែ ◌្ម រ (ខុស)

ដោយសាររូបមន្តអាស្រ័យលើបរិបទ ក្ដារចុចខ្មែរអង្គរអាចកែកំហុសដូចមានក្នុងពាក្យទី២ឱ្យចេញមកមានលំដាប់លំដោយដូចក្នុងពាក្យទី១ ។

### ជើង + ◌្រ [U+17D2] [U+179A]

ដោយផ្អែកលើក្បួននៃការប្រកប បើមានជើង២នៅបន្តបន្ទាប់គ្នា ហើយជើង១ក្នុងចំណោមជើងទាំង២ជា ◌្រ [U+17D2] [U+179A] នោះជើង ◌្រ [U+17D2] [U+179A] ត្រូវនៅបន្ទាប់ពីជើង១ទៀត ។

- កញ្ជ្រឹល = ក ញ ◌្ជ ◌្រ ◌ឹ ល (ត្រូវ)
- កញ្ជ្រឹល = ក ញ ◌្រ ◌្ជ ◌ឹ ល (ខុស)

ដូចឃើញស្រាប់ហើយថា លំដាប់លំដោយនៃជើងក្នុងពាក្យទាំង២មិនដូចគ្នាទេ តែពាក្យដែលបង្ហាញលើអេក្រង់គឺដូចគ្នាតែម្តង ។ អញ្ចឹង មិនខុសពីករណីខាងលើៗទេ ក្តារចុចខ្មែរអង្គរអាចប្តូរលំដាប់លំដោយនៃជើងទាំង២នេះដោយស្វ័យប្រវត្តិ ។ ជាលទ្ធផល យើងនឹងបានពាក្យដែលមើលទៅដូចគ្នានិងមានលំដោយលំដោយកុងសង់ស៊ីសគ្នាថែមទៀតផង ។

### ជើង + វណ្ណយុត្តប្តូរមូលភេទ + ស្រៈ

នេះជាករណីដែលលំដាប់លំដោយតួអក្សរមិនប្រាកដប្រជាក្នុងយូនីកូដស្តង់ដា ។ យូនីកូដស្តង់ដាជំនាន់៤.0និងលើសពីនេះឱ្យដាក់វណ្ណយុត្តប្តូរមូលភេទនៅចន្លោះរវាងព្យញ្ជនៈនិងជើង ប៉ុន្តែយូនីកូដស្តង់ដា៣.0ឱ្យដាក់បន្ទាប់ពីជើង ។ ក្តារចុចខ្មែរអង្គរយល់ស្របនឹងយូនីកូដស្តង់ដា៣.0 ហើយយកលំដាប់លំដោយនោះមកធ្វើជាបទដ្ឋាន ។ បើគេវាយវណ្ណយុត្តប្តូរមូលភេទមុនដាក់ជើង នោះលំដាប់លំដោយនេះនឹងត្រូវបានប្តូរដោយគ្មានការរំខាន ។

ម ◌៉ ◌្យ ◌ា ង ⇒ ម ◌្យ ◌៉ ◌ា ង

### វណ្ណយុត្តប្តូរមូលភេទ + ស្រៈ

វណ្ណយុត្តប្តូរមូលភេទគួរតែវាយមុនស្រៈ ។ (សូមមើលចំណុចខាងលើ

### ស្រៈមាននិគហិត [U+17C6]

យូនីកូដស្តង់ដាចាត់ទុកនិគហិតជាសញ្ញា ទោះបីជាវាមានតួនាទីស្រដៀងស្រៈនិស្ស័យក៏ដោយ ។ គេច្រើនផ្សំវាជាមួយស្រៈនិស្ស័យ ឧទា. ◌ុ [U+17BB] ◌ា [U+17B6] ហើយវាត្រូវនៅទីតាំងបន្ទាប់ពីស្រៈទាំងនេះ ។

ក ◌ំ ◌ុ ⇒ ក ◌ុ ◌ំ

ក ◌ំ ◌ា ⇒ ក ◌ា ◌ំ

### ស្រៈ ◌ោ [U+17C4] និងស្រៈ ◌ើ [U+17BE]

គេអាចច្រឡំវាយស្រៈទាំង២នេះដោយផ្សំស្រៈ ◌ា [U+17B6] និងស្រៈ ◌េ [U+17C1] ហើយស្រៈ ◌េ [U+17C1] និងស្រៈ ◌ី [U+17B8] ។ បើគេវាយផ្សំគ្នាបែបនេះ ក្តារចុចខ្មែរអង្គរនឹងប្តូរបន្សំនោះទៅជា ◌ោ [U+17C4] និង ◌ើ [U+17BE] ដែលជាស្រៈត្រឹមត្រូវពិតប្រាកដ ។

### ជើងមើលទៅដូចគ្នា

ជើង២មើលទៅដូចគ្នាបេះបិទ តែតាមពិតមានលេខកូដយូនីកូដខុសគ្នា (◌្ដ [U+17D2] [U+178A] and ◌្ត [U+17D2] [U+178F]) ។ តាមរូបមន្តការប្រកបជើងទី១ត្រូវដាក់បន្ទាប់ ណ [U+178E] ហើយទី២ត្រូវដាក់បន្ទាប់ ន [U+1793] ។

## ការបង្វិលស្រៈ

យើងមិនអាចដាក់ស្រៈ២បន្តបន្ទាប់គ្នាបានទេ បើវាយស្រៈ១ហើយវាយស្រៈ១ទៀត ស្រៈដែលទើបនឹងវាយនោះនឹងជំនួសស្រៈដែលវាយមុន ។ ឧទាហរណ៍ បើយើងបានវាយស្រៈ ◌ា [U+17B6] រួចហើយវាយស្រៈ ◌ែ [U+17C2] នោះស្រៈ ◌ែ [U+17C2] នឹងជំនួសស្រៈ ◌ា [U+17B6] ។

**ចំណាំ ៖**

ការបង្វិលស្រៈនឹងមិនកើតឡើងទេក្នុងករណីខាងក្រោម ៖

- បើស្រះទី១ជាស្រះ េ[U+17C1] ស្រះទី២ជាស្រះ ី[U+17B8] នោះលទ្ធផលគឺស្រះ ើ[U+17BE] មិនមែនស្រះ ី[U+17B8] ទេ ។
- បើស្រះទី១ជាស្រះ េ[U+17C1] ហើយស្រះទី២ជា ា[U+17B8] ឬបញ្ច្រាសមកវិញ នោះលទ្ធផលគឺជាស្រះ ោ[U+17C4] ព្រោះថាការបង្វិលមិនកើតឡើងទេក្នុងករណីនេះ ។
- បើស្រះទី១ជាស្រះលើ[3] ហើយស្រះទី២ជាស្រះ ុ[U+17BB] ឬបញ្ច្រាសមកវិញ នោះការបង្វិលមិនកើតឡើងទេ ហើយលទ្ធផលគឺជាវណ្ណយុត្តប្ដូរមូលភេទដែលស៊ីនឹងបរិបទ ។ ឧទាហរណ៍ថា គេវា "ស ី ុ" ឬ "ស ុ ី" នោះវានឹងស្វ័យកែតម្រូវទៅជា "ស៊ី (ស ៊ ី)" ចំណែកឯ "ម ី ុ" ឬ "ម ុ ី" នឹងក្លាយទៅជា "ម៉ី (ម ៉ ី)" ។
- ពេលដាក់ ុ [U+17BB] បន្ទាប់ពី ាំ នោះស្រះ ុ នឹងប្ដូរទៅជាវណ្ណយុត្តប្ដូរមូលភេទ ហើយដាក់នៅពីខាងមុខស្រះ ាំ ។ ឧទាហរណ៍៖
  - សាំ + ុ ⇒ ស៊ាំ (ស ៊ ាំ) ហើយ
  - មាំ + ុ ⇒ ម៉ាំ (ម ៉ ាំ) ។
- ពេលដាក់ស្រះ ា ឬស្រះ ុ បន្ទាប់ពីស្រះ ំ នោះទីតាំងត្រូវប្ដូរច្រាសមកវិញ ។ ឧទាហរណ៍៖
  - ក + ំ + ុ ⇒ កុំ (ក ុ ំ) ហើយ
  - ក + ំ + ា ⇒ កាំ (ក ា ំ) ។
  - 

## បម្រាម/សំឡេងព្រមាន

- មិនអនុញ្ញាតឱ្យដាក់ស្រះ២ដាក់បន្តបន្ទាប់គ្នានៅក្នុងព្យាង្គតែ១ ។
- មិនអនុញ្ញាតដាក់បន្តក់បន្ទាប់ពីស្រះ វណ្ណយុត្តដូចស្រះ[4] វណ្ណយុត្តប្ដូរមូលភេទ ឬ ក៏ជើងឡើយ ។
- មិនអនុញ្ញាតឱ្យដាក់សញ្ញាដាក់ជើង (្) ២បន្តបន្ទាប់គ្នា ។
- មិនអនុញ្ញាតឱ្យដាក់វណ្ណយុត្តប្ដូរមូលភេទ២បន្តបន្ទាប់គ្នា ។

## តួអក្សរវាយច្រឡំ

| ល.រ. | គេច្រឡំវាយ ... | ត្រូវស្វ័តកែតម្រូវជា... |
|---|---|---|
| ១ | ទ្ឋ (ទ ្ឋ) | ឡ |
| ២ | បួ (ប ួ) | ឫ |
| ៣ | បួុ (ប ួ ុ) | ឬ |
| ៤ | ពួា (ពួ ា) | ញ |
| ៥ | ព្ញា (ព្ញ ា) | ញ |
| ៦ | ពួ (ព ួ) | ឮ |
| ៧ | ពួុ (ព ួ ុ) | ឮ |
| ៨ | ព្ឋ (ព ្ឋ) | ឭ |
| ៩ | ឧិ (ឧ ិ) | ឱ |

[3] គេចាត់ទុកស្រះ ិ[U+17B7] ី[U+17B8] ឹ[U+17B9] ឺ[U+17BA] ើ[U+17BE] និង ាំ[U+17B6] [U+17C6] ជាស្រះលើ ។
[4] តួអក្សរទាំងនេះ(ំ[U+17C6] ះ[U+17C7] និង ៈ[U+17C8])មានតួនាទីស្រដៀងស្រះ ។

| | | |
|---|---|---|
| ១០ | ឧ៊ (ឧ ◌៊) | ឱ |
| ១១ | ឧ៌ (ឧ ◌៌) | ឱ |
| ១២ | ដ្ឋ (ដ ◌្ឋ) | ដ្ឋ |
| ១៣ | ទ្ធ (ទ ◌្ធ) | ទ្ធ |